# Joint Statement of Civil Society Support for Children Deprived of Liberty in Cambodia

Phnom Penh, 5 May 2021

We, the undersigned organizations, congratulate the successful National Launch of the United Nations Global Study on Children Deprived of Liberty ("Global Study") in Cambodia.

We appreciate and respect the voices of children deprived of liberty that were raised at the National Launch through the sharing of personal experiences and the joint statement by the Child and Youth-Led Networks, which highlighted the challenges faced by these children and their requests to the Cambodian government. We empathize with the troubles, concerns, and pain expressed by the children, and we fully support their ten concrete requests made to the government for preventing situations that deprive the liberty of children and for protecting the rights and wellbeing of children already in those situations.

We agree with the Global Study that deprivation of liberty for children is a deprivation of their childhood and a form of structural violence against children. We underscore the importance of framing our understanding of deprivation of liberty to be inclusive of children in a wide array of situations, including children in conflict with the law, children in prisons with their primary caregivers, and children living in institutions and centers. We affirm that children deprived of liberty are entitled to the same rights as all other children, but also recognize that they are in particularly vulnerable situations with specific needs that require specialized attention.

We acknowledge that Cambodia has made significant progress over the years in establishing a child justice system, enhancing child protection mechanisms, actively deinstitutionalizing children, and fighting to end violence against children, including as a Pathfinding Country. However, there is still work to be done, and the Global Study can provide helpful guidance to support the government's ongoing efforts.

We as members of the civil society feel a responsibility to support children around the country who are facing deprivation of liberty. We will join forces and collaborate with the communities to study and address the root causes resulting in deprivation of liberty for children at the individual and systemic levels, as well as to improve the diverse conditions faced by children currently deprived of liberty in a rights-based and child-friendly manner. We will pursue a holistic and interdisciplinary approach, encompassing child justice, child protection, social protection, education, and more.

We declare our firm commitment to work closely with the government, in meaningful partnership with children, to achieve positive outcomes for all children in Cambodia, both as a measure of prevention and of response to deprivation of liberty for children. To best prioritize and strategize our efforts, and to find the best and most promising solutions, we will engage both domestically and internationally, including through the 2021 World Congress on Justice with Children.

We are determined to advance and bolster our collective efforts to work for and with children, fully respecting their voices and pursuing an inclusive and effective approach that is sensitive to the needs and circumstances of children deprived of liberty.

*This statement has been jointly prepared by the following civil society members of the Organizing Committee for the National Launch of the Global Study in Cambodia:*

1. Adolescent and Youth Reference Group
2. Cambodian Children and Young People Movement for Child Rights
3. Child Advocate Network
4. Child Rights Coalition Cambodia
5. Legal Aid of Cambodia – member of the NGO Panel for the Global Study
6. Global Campus of Human Rights
7. Global Initiative on Justice with Children – represented by Terre des hommes

*This statement is joined by the following civil society speakers at the National Launch:*

1. Save the Children
2. This Life Cambodia

*This statement is endorsed by the following civil society organizations in Cambodia:*

1. Buddhism for Social Development Action
2. Cambodia Against Child Trafficking Network (Cambodia ACTs)
3. Cambodian Center for Human Rights
4. Cambodian Center for the Protection of Children's Rights
5. Cambodian Human Rights Action Coalition
6. Cambodian Human Rights and Development Association (ADHOC)
7. CARE International in Cambodia
8. Chab Dai Coalition
9. Children In Families Organization
10. Children's Rights International
11. Community Council for Development Organization
12. Community Legal Education Center
13. First Step Cambodia
14. Gender and Development for Cambodia
15. Hagar International in Cambodia
16. Italian Association for Aid to Children
17. Krousar Thmey
18. Legal Support for Children and Women
19. Phare Ponleu Selpak Association
20. Plan International Cambodia
21. SOS Children's Villages International
22. Terre des Hommes Netherlands
23. The Cambodian NGO Committee on CEDAW (NGO-CEDAW)
24. Women Organization for Modern Economy and Nursing

*This statement is also endorsed by the NGO Panel for the Global Study on Children Deprived of Liberty, a group of 170 civil society organizations around the world that is co-convened by Defence for Children International and Human Rights Watch. The NGO Panel has been an important partner in the initiation and completion of the Global Study, as well as in its implementation and follow-up.*

https://childrendeprivedofliberty.info/

---

The National Launch of the United Nations Global Study on Children Deprived of Liberty in Cambodia was held on 22 April 2021 through an online platform, attended by children and youth, government officials, civil society organizations, United Nations agencies, academia, development partners, and members of the public in Cambodia and abroad. Preparations involved pre-session consultations with children and engagement with the key line ministries. These voices, along with the voices of the civil society were highlighted during the National Launch, as a method of sharing information, recommendations, and commitments.

The Cambodian Preparatory Meeting for the 2021 World Congress on Justice with Children was also held immediately following the National Launch, resulting in productive discussions around the challenges, priorities, and promising practices in the field of child justice in Cambodia, and paving the way for better coordination among child justice organizations.

For more information, please contact the Organizing Committee at GSCDLCambodia@gmail.com. The Global Study can be accessed at https://omnibook.com/Global-Study-2019 and https://nochildbehindbars.com.

# សេចក្តីថ្លែងការណ៍រួម

# របស់សង្គមស៊ីវិល

# ស្តីពីការដកហូតសិទ្ធិសេរីភាពកុមារនៅប្រទេសកម្ពុជា

រាជធានីភ្នំពេញ ថ្ងៃទី ៥ ខែ ឧសភា ឆ្នាំ ២០២១

យើងជាអង្គការដែលបានចុះហត្ថលេខា សូមអបអរសាទចំពោះការផ្សព្វផ្សាយថ្នាក់ជាតិនៃការសិក្សាស្រាវជ្រាវជាសកលរបស់អង្គការសហប្រជាជាតិ ស្តីពីការដកហូតសិទ្ធិសេរីភាពកុមារ (ការសិក្សាស្រាវជ្រាវជាសកល) ដែលរៀបចំឡើងនៅក្នុងប្រទេសកម្ពុជាថ្ងៃនេះ។

យើងសូមកោតសរសើរ និងគោរពសម្លេងរបស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាពហើយដែលបានលើកឡើងនៅក្នុងការផ្សព្វផ្សាយថ្នាក់ជាតិ តាមរយៈការចែករំលែកបទពិសោធន៍ផ្ទាល់ខ្លួន និងសេចក្តីថ្លែងការណ៍រួមនៃបណ្តាញដែលដឹកនាំដោយកុមារ និងយុវជន ដែលបង្ហាញពីបញ្ហាប្រឈមដែលកុមារទាំងនោះបានជួបប្រទះ និងសំណូមពររបស់ពួកគេទៅកាន់រដ្ឋាភិបាលកម្ពុជា។ យើងយល់ពី បញ្ហា កង្វល់ និងការឈឺចាប់ដែលបង្ហាញដោយកុមារ ហើយយើងគាំទ្រយ៉ាងពេញទំហឹងនូវសំណូមពរជាក់ស្តែងចំនួន ១០ របស់ពួកគេដែលបានដាក់ជូនទៅកាន់រដ្ឋាភិបាលដើម្បីការពារស្ថានភាពនានាដែលដកហូតសិទ្ធិសេរីភាពកុមារ និងដើម្បីការពារសិទ្ធិ និងសុខុមាលភាពរបស់កុមារនៅក្នុងស្ថានភាពទាំងនោះ។

យើងយល់ស្របនឹងការសិក្សាស្រាវជ្រាវជាសកលថា ការដកហូតសិទ្ធិសេរីភាពកុមារគឺជាការដកហូតសិទ្ធិសេរីភាពកុមារភាព និងជាទម្រង់នៃអំពើហិង្សាលើកុមារ។ យើងគូសបញ្ជាក់ពីសារៈសំខាន់នៃការយល់ដឹងអំពីការដកហូតសិទ្ធិសេរីភាព ដោយរួមមានកុមារនៅក្នុងស្ថានភាពជាច្រើន ដូចជាកុមារទំនាស់នឹងច្បាប់ កុមារនៅក្នុងពន្ធនាគារជាមួយម្តាយ និងកុមារដែលរស់នៅក្នុងមណ្ឌលជាដើម។ យើងសូមអះអាងថាកុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព មានសិទ្ធិដូចគ្នានឹងកុមារដទៃទៀតដែរ ប៉ុន្តែយើងក៏ទទួលស្គាល់ផងដែរថាពួកគេស្ថិតនៅក្នុងស្ថានភាពងាយរងគ្រោះ ដោយសារតែពួកគេមានតម្រូវការពិសេសដែលត្រូវឆ្លើយតបដោយអ្នកជំនាញ។

យើងទទួលស្គាល់ថាប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះក្នុងការបង្កើតប្រព័ន្ធយុត្តិធម៌សម្រាប់កុមារ ការពង្រឹងយន្តការការពារកុមារ ការធ្វើសមាហរណកម្មកុមារចេញពីមណ្ឌល និងការទប់ស្កាត់អំពើហិង្សាលើកុមារ រាប់បញ្ចូលទាំងការចូលជាសមាជិកនៃប្រទេសដែលឈានមុខគេក្នុងការទប់ស្កាត់អំពើហិង្សាផងដែរ។ តែទោះបីជាយ៉ាងណាក៏ដោយក៏នៅតែមានការងារ

ដែលត្រូវធ្វើបន្តទៀត ហើយការសិក្សាស្រាវជ្រាវជាសកលអាចផ្តល់នូវការណែនាំដ៏មានប្រយោជន៍ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល។

ក្នុងនាមយើងជាសមាជិកនៃសង្គមស៊ីវិល យើងមានការទទួលខុសត្រូវក្នុងការគាំទ្រដល់កុមារទាំងឡាយណាដែលកំពុងប្រឈមនឹងការដកហូតសិទ្ធិសេរីភាព។ យើងនឹងចូលរួមសហការជាមួយសហគមន៍ដើម្បីសិក្សា និងដោះស្រាយឫសគល់នៃបញ្ហាដែលបណ្តាលឲ្យមានការដកហូតសិទ្ធិសេរីភាពកុមារនៅក្នុងកម្រិតបុគ្គល និងលក្ខណៈជាប្រព័ន្ធ ក៏ដូចជាដើម្បីកែរលម្អរស្ថានភាពផ្សេងៗដែលកុមារត្រូវបានដកហូតសិទ្ធិសេរីភាពកំពុងជួបប្រទះនាពេលបច្ចុប្បន្នដោយផ្អែកលើសិទ្ធិ និងបែបបទកុមារមេត្រី។ យើងនឹងអនុវត្តនូវវិធីសាស្ត្ររួម និងអន្តរកម្មមួយ រួមមានដូចជាយុត្តិធម៌កុមារ ការការពារកុមារ ការគាំពារសង្គម ការអប់រំ ។ល។

យើងសូមប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការធ្វើការយ៉ាងជិតស្និទ្ធជាមួយរដ្ឋាភិបាល ក្នុងភាពជាដៃគូប្រកបដោយអត្ថន័យជាមួយកុមារ ដើម្បីទទួលបានលទ្ធផលជាវិជ្ជមានសម្រាប់កុមារទាំងអស់នៅក្នុងប្រទេសកម្ពុជាដោយផ្តោតលើវិធានការបង្ការ និងការឆ្លើយតបចំពោះការដកហូតសិទ្ធិសេរីភាពសម្រាប់កុមារ។ ដើម្បីចាត់អាទិភាព និងរៀបចំយុទ្ធសាស្ត្រនៃកិច្ចខិតខំប្រឹងប្រែងរបស់យើងឲ្យល្អបំផុត និងដើម្បីស្វែងរកដំណោះស្រាយដែលល្អ និងជោគជ័យបំផុត យើងនឹងចូលរួមទាំងក្នុងស្រុក និងអន្តរជាតិ រួមមានការចូលរួមសមាជពិភពលោកស្តីពីយុត្តិធម៌សម្រាប់កុមារឆ្នាំ ២០២១ ។

យើងប្តេជ្ញាថាជម្រុញ និងគាំទ្រនូវកិច្ចខិតខំប្រឹងប្រែងរួមគ្នាដើម្បីធ្វើការជាមួយកុមារ ដោយគោរពនូវសម្លេងរបស់ពួកគេ និងស្វែងរកវិធីសាស្ត្រដែលមានលក្ខណៈពេញលេញ និងមានប្រសិទ្ធិភាពដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការ និងកាលៈទេសៈរបស់កុមារដែលត្រូវបានដកហូតសិទ្ធិសេរីភាព។

*សេចក្តីថ្លែងការណ៍នេះត្រូវបានរៀបចំរួមគ្នាដោយសមាជិកសង្គមស៊ីវិលដូចខាងក្រោមនៃគណៈកម្មាធិការរៀបចំសម្រាប់ការផ្សព្វផ្សាយថ្នាក់ជាតិស្តីពីការសិក្សាស្រាវជ្រាវជាសកលនៅកម្ពុជា៖*

១. ក្រុមតំណាងយុវវ័យនិងយុវជន
២. សមាគមចលនាកុមារ និងយុវជនកម្ពុជាដើម្បីសិទ្ធិកុមារ
៣. បណ្តាញកុមារអ្នកតស៊ូមតិ
៤. អង្គការសម្ពន្ធសិទ្ធិកុមារកម្ពុជា
៥. អង្គការជំនួយ ផ្នែកច្បាប់នៃកម្ពុជា – សមាជិកនៃ NGO Panel for the Global Study
៦. Global Campus of Human Rights
៧. Global Initiative on Justice with Children – តំណាងដោយអង្គការ Terre des hommes

*សេចក្តីថ្លែងការណ៍នេះ ត្រូវបានចូលរួមដោយវាគ្មិន មកពីសង្គមស៊ីវិលដូចខាងក្រោមនៅក្នុងការផ្សព្វផ្សាយថ្នាក់ជាតិ៖*

១. Save the Children
២. អង្គការជីវិតនៅកម្ពុជា

*សេចក្តីថ្លែងការណ៍នេះ ត្រូវបានគាំទ្រដោយអង្គការសង្គមស៊ីវិលដូចខាងក្រោមនៅក្នុងប្រ ទេសកម្ពុជា៖*

១. អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម
២. អង្គការសម្ព័ន្ធអង្គការមិនមែនរដ្ឋាភិបាលប្រឆាំងការជួញដូរកុមារនៅកម្ពុជា
៣. មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
៤. អង្គការមជ្ឈមណ្ឌលកម្ពុជាដើម្បីការពារសិទ្ធិកុមារ
៥. អង្គការសម្ព័ន្ធភាពការពារសិទ្ធិមនុស្សកម្ពុជា
៦. សមាគមការពារសិទ្ធិមនុស្ស និង អភិវឌ្ឍន៍នៅកម្ពុជា
៧. អង្គការឃែរអន្តរជាតិប្រចាំកម្ពុជា
៨. អង្គការសម្ព័ន្ធចាប់ដៃ
៩. អង្គការកុមារក្នុងគ្រួសារ
១០. អង្គការសិទ្ធិកុមារអន្តរជាតិ
១១. អង្គការប្រឹក្សាសហគមន៍ដើម្បីអភិវឌ្ឍន៍
១២. មជ្ឈមណ្ឌលអប់រំច្បាប់សម្រាប់សហគមន៍
១៣. ជំហានដំបូងកម្ពុជា
១៤. អង្គការយេនឌ័រនិងអភិវឌ្ឍន៍ដើម្បីកម្ពុជា
១៥. អង្គការមូលនិធិហាការអន្តរជាតិប្រចាំនៅកម្ពុជា
១៦. អង្គការអ៊ីតាលីជួយសង្គ្រោះកុមារ
១៧. អង្គការគ្រួសារថ្មី
១៨. អង្គការជំនួយផ្លូវច្បាប់ដលើកុមារ និងស្រ្ត
១៩. សមាគមហ្សារ ពន្លឺសិល្បៈ
២០. Plan International Cambodia
២១. អង្គការភូមិកុមារSOS អន្តរជាតិ
២២. Terre des Hommes Netherlands
២៣. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងលើស្រ្តី
២៤. អង្គការនារីអភិវឌ្ឍន៍សេដ្ឋកិច្ច និងអនាម័យ

*សេចក្តីថ្លែងការណ៍នេះក៏មានការចូលរួមពី NGO Panel for the Global Study on Children Deprived of Liberty, ដែលមាន អង្គការសង្គមស៊ីវិលចំនួន១៧០ នៅជុំវិញពិភពលោកជាសមាជិក សហការណ៍ដោយ Defence for Children International និង Human Rights Watchផងដែរ. NGO Panel ជាដៃគូយ៉ាងសំខាន់នៅក្នុងការបង្កើតឲ្យមានគំនិតផ្តួចផ្តើម និងបញ្ចប់លើការសិក្សាជាសកលនេះរួមជាមួយនឹងការតាមដានលើការអនុវត្តផងដែរ។*

https://childrendeprivedofliberty.info/

---

ការផ្សព្វផ្សាយថ្នាក់ជាតិអំពីលទ្ធផលនៃការសិក្សាស្រាវជ្រាវជាសកលរបស់អង្គការសហប្រជាជាតិស្តីពីការដកហូតសិទ្ធិសេរីភាពកុមារ នៅក្នុងប្រទេសកម្ពុជាត្រូវបានប្រព្រឹត្តទៅនៅថ្ងៃទី ២២ ខែ មេសា ឆ្នាំ ២០២១ តាមអនឡាញដែលមានការចូលរួមពីកុមារ និងយុវជន មន្ត្រីរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ទីភ្នាក់ងារអង្គការសហប្រជាជាតិ អ្នកសិក្សា ដៃគូអភិវឌ្ឍន៍ និងសមាជិកសាធារណៈនៅកម្ពុជា បរទេស។ ការរៀបចំការផ្សព្វផ្សាយនេះបានធ្វើឡើង ដោយមានការពិគ្រោះយោបល់ជាមុនជាមួយកុមារ និងការចូលរួមពីក្រសួងដែលពាក់ព័ន្ធសំខាន់ៗ។ សម្លេងទាំងនោះ រួមជាមួយសម្លេងរបស់សង្គមស៊ីវិលត្រូវបានគេរំលេចឡើងក្នុងពេលផ្សព្វផ្សាយថ្នាក់ជាតិ ដែលជាវិធីនៃការចែលរំលែកព័ត៌មាន អនុសាសន៍ និងការប្តេជ្ញាចិត្ត។

កិច្ចប្រជុំក្រុមបច្ចេកទេសដើម្បីត្រៀមរៀបចំសមាជពិភពលោកស្តីពីយុត្តិធម៌សម្រាប់កុមារឆ្នាំ ២០២១ ក៏ត្រូវបានធ្វើឡើងភ្លាមៗបន្ទាប់ពីកម្មវិធីផ្សព្វផ្សាយថ្នាក់ជាតិ ដោយមានការពិភាក្សាប្រកបដោយផ្លែផ្កាជុំវិញបញ្ហាប្រឈម អាទិភាព និងការអនុវត្តជាក់ស្តែងនៅក្នុងវិស័យយុត្តិធម៌កុមារនៅកម្ពុជា និងត្រួសត្រាយផ្លូវសម្រាប់ការសម្របសម្រួលឲ្យកាន់តែល្អប្រសើរក្នុងចំណោមអង្គការយុត្តិធម៌កុមារ។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងគណៈកម្មាធិការរៀបចំតាមរយៈ៖ GSCDLCambodia@gmail.com ។ ការសិក្សាស្រាវជ្រាវជាសកលអាចចូលមើលបានតាមរយៈ៖ https://omnibook.com/Global-Study-2019 និង https://nochildbehindbars.com ។